គម្រោងបង្ហាញបច្ចេកវិទ្យា ដើម្បីបង្កើនផលិតភាពជុំវិញតំបន់ទន្លេសាប

Tonle Sap Technology Demonstrations for Productivity Enhancement (TSTD)

ADB TA 7305-CAM

# សៀវភៅណែនាំបច្ចេកទេស

## ផលិតកម្មបណ្តុះផ្សិតអំបោះ




រៀបរៀងដោយ: លោក សាន ឆក

អ្នកជំនាញការប្រាស្រ័យព័ត៌មានកសិកម្ម

ខែ មករា ឆ្នាំ ២០១២

ទូរសព្ទ ០១២ ៩៥៦ ២០៧

អ៊ីម៉ែល san_chhork@yahoo.com

# តារាងមាតិកា


| | |
|---|---|
| ១. សេចក្តីផ្តើម | ៣ |
| ២. សារៈប្រយោជន៍នៃការបណ្តុះផ្សិតអំបោះ | ៣ |
| ៣. ការជ្រើសរើសទីតាំង និង ការសាងសង់រោងសំរាប់បណ្តុះផ្សិតអំបោះ | ៣ |
| ៣.១. ទីកន្លែង/ទីតាំងបណ្តុះផ្សិត | ៣ |
| ៣.២. ការសាងសង់រោងបណ្តុះផ្សិត | ៤ |
| ៤. សំភារៈ/ឧបករណ៍សំរាប់បណ្តុះផ្សិតអំបោះ | ៤ |
| ៥. វត្ថុធាតុផ្សំ និង រូបមន្តឬកំរឹតធាតុផ្សំសំរាប់បណ្តុះផ្សិតអំបោះ | ៥ |
| ៥.១. សារធាតុផ្សំសំខាន់ៗ | ៥ |
| ៥.២. កំរឹត/រូបមន្តសារធាតុផ្សំ | ៥ |
| ៦. លំដាប់លំដោយបច្ចេកទេសបណ្តុះផ្សិតអំបោះ | ៦ |
| ៦.១. ការលាយល្បាយ | ៦ |
| ៦.២. ការស្រោចទឹកក្នុងល្បាយ | ៦ |
| ៦.៣. ការផ្អាប់ល្បាយ | ៧ |
| ៦.៤. ការច្រកល្បាយចូលក្នុងថង់បណ្តុះផ្សិតអំបោះ | ៨ |
| ៦.៥. ការចំហុយថង់ផ្សិតដែលបានច្រកល្បាយ | ៨ |
| ៦.៦.ការបញ្ចូលមេផ្សិតក្នុងថង់ផ្សិតបានចំហុយ | ១០ |
| ៦.៧. ការផ្អាប់/បន្ទំថង់ផ្សិតក្នុងរោងបន្ទុំ | ១០ |
| ៦.៨. ការព្យួរថង់ផ្សិត និងស្រោចទឹក | ១១ |
| ៧. ការប្រមូលផល និង ការថែទាំ | ១២ |
| ៨. លទ្ធផលបច្ចេកទេស | ១៣ |
| ៩. លទ្ធផលសេដ្ឋកិច្ច | ១៣ |

# ការបណ្តុះផ្សិតអំបោះ

## ១. សេចក្តីផ្តើម៖

ផ្សិតអំបោះដុះលូតលាស់នៅក្នុងបរិស្ថានធម្មជាតិសើម មិនស្ងួតក្រៀម និង លើរុក្ខជាតិពុកផុយដែលមានសំណើមពី៦០ទៅ៧០ភាគរយនិងសីតុណ្ហភាពពី២៥ទៅ២៨អង្សាសេ ។ វាជាដំណាំម្យ៉ាងដែលត្រូវការសំណើមនិងភាពត្រជាក់គ្រប់ពេលវេលាហើយមិនចូលចិត្តឲ្យគេរំខានឡើយក្នុងពេលកំពង់លូតលាស់។

ផ្សិតអំបោះគឺជាប្រភេទផ្សិតដែលងាយស្រួលបណ្តុះ ការចំណាយថវិកាតិច កំលាំងពលកម្មតិច វត្ថុធាតុដើមយកមកប្រើប្រាស់ជាកាកសំណល់ងាយស្រួលរកមកបណ្តុះ (អាចម៍រណារ ស្នូលគរ កន្ទុកស្រូវ ម្សៅដំណើប ដីអ៊ុយរេ និងកំបោរស) ប៉ុន្តែវាត្រូវតែទាមទារមានការអំណត់ព្យាយាមជាពិសេសបំផុតផ្តោតលើការអនុវត្តតាមលក្ខណៈបច្ចេកទេសនិងអនាម័យឲ្យបានស្អាតជានិច្ច។

## ២. សារៈប្រយោជន៍នៃការបណ្តុះផ្សិតអំបោះ ៖

- ផ្តល់ជាបន្លែដ៏មានឱជារស
- ជួយបង្កើនប្រាក់ចំណូលបន្ថែមដល់គ្រួសារ
- បង្កើនមុខរបរក្បែរផ្ទះដល់គ្រួសារ
- មានសារធាតុសរីរាង្គនិងរ៉ែប្រើសំរាប់ព្យាបាលជម្ងឺផ្សេងៗ ដែលបណ្តាលមកពីកង្វះសារធាតុបំប៉ន និងទប់ស្កាត់ការពារ ព្យាបាលជម្ងឺខ្វះឈាមក្រហម(សារជាតិម្យ៉ាងគឺ Folic Acide) និងជីវជាតិផ្សេងៗដូចជា៖ ជាតិដែក (ជួយបង្កើតគ្រាប់ឈាមក្រហម) សូដ្យូមនិងប៉ូតាស្យូម (ជួយបង្កើនលំនិងទឹកនៅក្នុងខ្លួនយើង) វិតាមីនបេ១ (ជួយការពារកុំឲ្យមានជម្ងឺស្ពឹក) កាលស្យូម (ជួយឆ្អឹងឲ្យលូតលាស់និងសាច់ដុំបេះដូងឲ្យមានកំលាំង) និងប្រូតេអីន។

## ៣. ការជ្រើសរើសទីតាំង និង ការសាងសង់រោងសំរាប់បណ្តុះផ្សិតអំបោះ៖

### ៣.១. ទីកន្លែង/ទីតាំងបណ្តុះផ្សិត

- ធ្វើនៅក្រៅផ្ទះ នៅក្រោមផ្ទះ (បើសិនក្រោមផ្ទះនោះមានកន្លែងធំទូលាយ)
- រោងទំហំ ៥មx៥ម អាចដាក់ថង់ផ្សិតបានចំនួន ៥០០០ កញ្ចប់
- នៅជិតប្រភពទឹក
- ដីមិនលិចទឹកនិង ដីមិនជាំទឹក
- ដីគ្មានសត្វល្អិតចង្រៃបំផ្លាញ (កណ្តៀរ ,ស្រមោច...)

### ៣.២. ការសាងសង់រោងបណ្តុះផ្សិត៖

- ត្រូវមានដំបូលប្រកស្លឹក
- ត្រូវមានជញ្ជាំងពទ្ធ័ជុំវិញ
- កំពស់រោងពី ៖ ២,៥-៣ ម៉ែត្រ
- លើកដីឲ្យរោងខ្ពស់ជាងដីធម្មតា៖២០-៣០ស.ម
- ចាក់ខ្សាច់អោយបានកំពស់ ៖៥-១០ ស.ម
- រៀបចំខ្សែសំរាប់ចងចងបណ្តុះផ្សិត




រូបលេខ១: សកម្មភាពសាងសង់រោងផ្សិត

## ៤. សំភារៈ/ឧបករណ៍សំរាប់បណ្តុះផ្សិតអំបោះ


ថង់ច្រក


ជញ្ជីង


ធុងចំហុយ


កៅស៊ូកង


ក្រដាស់


ដែកទំរ


ខ្សែចងពន្ឡ


បង្គោល


កង


ប៉ោតទឹក


ប៉ាវ៉ាតង់


រនាស់


ចបកាប់

រូបលេខ២: សំភារៈសំរាប់បណ្តុះផ្សិតអំបោះ

## ៥. វត្ថុធាតុផ្សំ និង រូបមន្តឬកំរឹតធាតុផ្សំសំរាប់បណ្តុះផ្សិតអំបោះ

### ៥.១. សារធាតុផ្សំសំខាន់ៗ


អាចម៍រណាដើមកៅស៊ូ


កន្ទក់ម៉ត់ល្អ


កំបោរស


ជីអ៊ុយរ៉េ


មេផ្សិតអំបោះ


ម្សៅអង្ករដំណើប


<u>រូបលេខ៣</u>: វត្ថុធាតុផ្សំសំរាប់បណ្តុះផ្សិតអំបោះ

### ៥.២. កំរឹត/រូបមន្តសារធាតុផ្សំ៖

| | | |
|---|---|---|
| អាចម៍រណាដើមកៅស៊ូ | = | ១០០ គ.ក្រ |
| មេផ្សិតអំបោះ | = | ៣-៣,៥ ដប |
| កន្ទក់ម៉ត់ | = | ១០ គ.ក្រ |
| ម្សៅអង្ករដំណើប | = | ១ គ.ក្រ |
| កំបោរស | = | ០,៥ គ.ក្រ |
| ជីអ៊ុយរ៉េ | = | ០,៣ គ.ក្រ |

## ៦. លំដាប់លំដោយបច្ចេកទេសបណ្តុះផ្សិតអំបោះ

### ៦.១. ការលាយល្បាយ

- រែងអាចម៍រណារដើម្បីយកសំបកនិងចំណាំងឈើកៅស៊ូចេញ
- ត្រូវថ្លឹងវត្ថុធាតុដើមទាំងនោះទៅតាមរូបមន្តខាងលើឲ្យបានច្បាស់លាស់
- ដាក់ធាតុផ្សំនិមួយៗទៅតាមស្រទាប់
- លាយច្របល់ធាតុផ្សំទាំងនោះឲ្យបានសព្វល្អ (ត្រូវយកដៃជ្រោយល្បាយនោះ ដោយប្រើម៉ាស់ឬក្រម៉ាមករុំការពារច្រមុះ)



រូបលេខ៤: ដំណើរលាយល្បាយបណ្តុះផ្សិតអំបោះ

### ៦.២. ការស្រោចទឹកលើល្បាយ

ប្រមូលល្បាយទាំងនោះមកគជាដុំ រួចវែកល្បាយនោះឲ្យមានប្រហោង បន្ទាប់ស្រោចទឹក (ទឹកថ្លាស្អាត) នៅក្នុងប្រហោងនោះ  រួចយកដៃច្របល់ល្បាយជាមួយទឹកនោះឲ្យបានសព្វល្អ (អាចម៍រណារចំនួន  ១០០គ.ក្រ ដាក់ទឹក៨ប៉ោតប៉េ) ដែលមានសំណើមប្រហែល ៦០ទៅ៧០ ភាគរយ។



រូបលេខ៥: សកម្មភាពស្រោចទឹកលើល្បាយ